*គុណតម្លៃ*

*ការប្តេជ្ញាចិត្ត តម្លាភាព ភក្តីភាព យ សេចក្តីសុចរិត និង ភាពជាអ្នកបំរើ*

*ទស្សនៈវិស័យ*

*ប្រជាពលរដ្ឋមានទឹកប្រើប្រាស់សុខភាពអនាម័យ និងបរិស្ថានល្អដើម្បីអោយជីវិតបានប្រសើរឡើង។*

# ការពិពណ៌នាការងារ

***បេសកកម្ម:*** *លើកកម្ពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងបណ្តាលសហគមន៍ គោលដៅដោយ ប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។*

## ១. ការសង្ខេបពីមុខតំណែង

| | |
|---|---|
| **មុខតំនែងនៃការងារៈ** | បុគ្គលិកស្ម័គ្រចិត្តផ្នែកតំឡើងចំរោះទឹក។ |
| **ទីកន្លែងៈ** | **ខេត្តស្វាយរៀង** |
| **ខ្សែរយៈ និង បណ្តាញរាយការណ៍** | • អ្នកសំខាន់ដែលត្រូវរាយការណ៍ជូនគឺៈ ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក។<br>• ការទំនាក់ទំនងផ្សេងទៀតគឺជាមួយ គ្រួសារអ្នកទទួលផលក្នុងសហគមន៍ និងអ្នកទទួលផលផ្សេងទៀតដែលចូលរួមក្នុងកម្មវិធី ចំរោះទឹក តាមរយៈការ ផ្តល់បដិភាគជាហិរញ្ញវត្ថុ ពលកម្ម និងចូលរួម ក្នុងការអប់រំផ្សព្វផ្សាយផ្នែកសុខភាព-អនាម័យ។<br>• ការទំនាក់ទំនងផ្សេងទៀតគឺជាមួយ ប្រធានភូមិ, ក្រុមប្រឹក្សាឃុំ, គណកម្មាធិការអភិវឌ្ឍន៍ភូមិ ។ |
| **គោលបំណងនៃមុខតំណែងៈ** | • ធ្វើការជាមួយគំរោងដែលមានក្នុងសហគមន៍ ដើម្បី អោយពួកគេទទួលបាននូវទឹកប្រើប្រាស់ តាមការ រៀមចំតំឡើង ចម្រោះ និង ការអប់រំពីការប្រើប្រាស់ ធុងចម្រោះខ្សាច់ ។តាមដានចំពោះទឹកស្អាតបានដំឡើងរួចអប់រំ កែលំអនិងជំរុញលើកទឹកចិត្តអោយមាននិរន្ត ភាពក្នុងកាប្រើប្រាស់ចម្រោះទឹកស្អាត។<br>• ថតរូប គ្រួសារដែលទទួលបានធុងចម្រោះ។<br>• ធ្វើកំណត់ត្រាចំនួនធុងចម្រោះដែលផ្តល់អោយដល់គ្រួសារជាក្រុមគោលដៅក្នុង *GPS* និង *Iform Builder ។* |
| **ការប្រឈមមុខនឹងមុខតំណែងនេះគឺៈ** | • រៀបចំគំរោងការដំឡើងធុងចម្រោះក្នុងសហគមន៍។<br>• គ្រួសារទទួលផលទាំងអស់និងអ្នកស្ម័គ្រចិត្តទទួលបានការយល់ដឹងអំពីការប្រើប្រាស់ និងតំហែទាំធុងចម្រោះបានល្អ។<br>• គ្រួសារដែលរស់នៅក្នុងសហគមន៍ ទទួលបានទឹកស្អាតប្រើប្រាស់។ |

## ២. ភារកិច្ចសំខាន់ៗ

| ការទទួលខុសត្រូវច្បាស់លាស់: | សកម្មភាពការងារជាក់លាក់: |
|---|---|
| ការអភិវឌ្ឍន៍ និងការអប់រំ | • រៀបចំតំឡើង ធុងចម្រោះអោយបានត្រឹមត្រូវ ដោយមានការចូលរួមពីគ្រួសារដែលទទួលផល។<br>• ជួយផ្តល់ការបង្រៀនដល់គ្រួសារអោយយល់អំពីគុណភាពល្អរបស់ធុងចម្រោះ ។<br>• ពន្យល់ដល់គ្រួសារទទួលផលអំពីជំការនៃការថែរក្សាធុងចំរោះអោយបានត្រឹមត្រូវនិងបំផុសស្មារតីម្ចាស់ការ។ |
| ផ្តត់ផ្គង់ការគ្រប់គ្រង | • ជួយដល់តំណាងអង្គការស្អាតកម្ពុជា ផ្នែកកិច្ចការរដ្ឋបាល ក្នុងការរៀបចំការកត់ត្រា ចំនួនធុងចម្រោះ ដែលតំឡើង ហើយ និង បញ្ចូលទៅក្នុង ប្រព័ន្ធ GPS និង Iform Builder ធ្វើការ បាន់ប្រមាន ដោយផ្ទាល់មាត់អំពីការ ប្រើប្រាស់ ធុងចម្រោះដល់តំណាងអង្គការស្អាតកម្ពុជា។<br>• ថតរូបភាពសកម្មភាពកំពុងតំឡើងធុងចម្រោះដោយមានគ្រួសារទទួលផលចូលរួម។<br>• បំពេញការងារផ្សេងៗ ទៀតទៅតាមតំរូវការ របស់ប្រធានប្រចាំខេត្តស្នើសុំ ។ |
| អប់រំសហគមន៍ និង ទំនាក់ទំនង | • ជួយ ជំរុញ និង លើកទឹកចិត្តដល់ គ្រួសារដែលទទួលផល<br>• ជួយបង្រៀន និង ណែនាំពីការ ប្រើប្រាស់ ធុងចម្រោះដល់ សហគមន៍។<br>• ជួយបង្រៀន និង ណែនាំពីការ ប្រើប្រាស់ ធុងចម្រោះដល់ សហគមន៍។ |
| ការងារផ្សេងៗទៀត | • ជួយដល់ការងារផ្សេងៗទៀតតាមតំរូវការរបស់ ប្រធានប្រចាំខេត្ត។ |

## ៣. លក្ខណៈសម្បត្តិគ្រូវការ

| | <u>សំខាន់ត្រូវតែមាន:</u> |
|---|---|
| បទពិសោធន៍ | • បទពិសោធន៍ក្នុងការងារសហគមន៍ ឬការតំឡើង ចម្រោះ។<br>• បើកបររថយន្តបានកាន់តែប្រសើរ។ |
| ការសិក្សាអប់រំ និង វគ្គបណ្តុះ | បញ្ចប់ វិទ្យាល័យ ។ |

| | |
|---|---|
| **បណ្ដាលៈ** | |
| **ជំនាញៈ** | • **ជំនាញ បច្ចេកទេស**<br>• មានសមត្ថភាព និងជំនាញក្នុងការ ចំឡើង ធុងចម្រោះទៅគំរូរបស់ កម្មវិធី ។<br>• ធ្វើការងារ ដោយឯករាជម្ចាស់ការ និង បង្ហាញ ពីនំគិតថ្មីៗ ក្នុង ដំណើការ តំឡើង ធុងចម្រោះ ។<br>• មាន លទ្ធភាពក្នុងការ ណែនាំអំពីការលំហូទឹក ពី ធុងចំរោះ ។<br>• មាន លទ្ធភាពក្នុងកំណត់មុខនាទី នៃ ដំណើការ និង មុខងារនៃធុងចម្រោះ នៅពេលមានបញ្ហា។<br>**ជំនាញអភិវឌ្ឍន៍**<br>• អាចធ្វើការណែនាំ, ពន្យល់ និង ការថៃទាំ ធុងចម្រោះដល់អ្នកប្រើប្រាស់ ។ |
| **គុណសម្បត្តិផ្ទាល់ខ្លួនៈ** | ប្រកាន់ខ្ជាប់នូវតំលៃ និង បេសកកម្មរបស់ ស្អាត កម្ពុជា។<br>• សីលធម៌ការងារជាអាជីព។<br>• មានតម្លាភាពក្នុងការងារ និងហិរញ្ញវត្ថុ។<br>• មានបំណងធ្វើការក្នុងសហគមន៍។<br>• មានភាពបត់បែន។<br>• មានភាពប្រែប្រួលទៅនឹងស្ថានការណ៍។<br>• ប្រឹងប្រែងធ្វើការងារ។ |